# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

## សេចក្តីជូនដំណឹង

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សហការជាមួយសមាគមរោងចក្រកាត់ដេរនៅកម្ពុជា(GMAC) សហភាពសហព័ន្ធយុវជនកម្ពុជា (សសយក) អគ្គនាយកដ្ឋានវិទ្យុ និងទូរទស្សន៍បាយ័ន និងអង្គការសហជីព រៀបចំ **កម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ ២០១៩ (លើកទី៥) ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៣ ទិវាពលកម្មអន្តរជាតិ ១ ឧសភា ។**

១. ការចែក និងទទួលពាក្យ៖ ចាប់ពី ថ្ងៃចន្ទ ៦កើត ដល់ថ្ងៃសុក្រ ២រោច ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ១១ ដល់ថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ នៅទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ រាជធានី/ខេត្តទាំង២៥ ឬអាចទាញចេញពីគេហទំព័រ www.mlvt.gov.kh ឬ www.facebook.com/mlvt.gov.kh/ ឬទំនាក់ទំនងតាមទូរសព្ទ៖

- លោកស្រី ជា សុខេន ទូរសព្ទលេខ ០៧៧ ៧០០ ៧២៦ (មណ្ឌលរាជធានីភ្នំពេញ)
- លោក ព្រហ្ម ច័ន្ទវិចិត្រ ទូរសព្ទលេខ ០១៧ ៨៧៨ ៣៣១ ឬ ០៦៩ ៦៦៩ ៩៦៩ (មណ្ឌលខេត្តព្រះសីហនុ)
- លោក នួន សំបូរ ទូរសព្ទលេខ ០១២ ៦៤៦ ៦៧៩ ឬ ០៨៨ ៨ ៦៤៦ ៦៧៩ (មណ្ឌលខេត្តស្វាយរៀង)
- លោក ហុង ប្រកប ទូរសព្ទលេខ ០៧៦ ៧២៦ ២៦២៦ (មណ្ឌលខេត្តបន្ទាយមានជ័យ)

២. **វគ្គសម្ភាសន៍រើសបេក្ខភាព** នឹងប្រព្រឹត្តទៅតាមកាលបរិច្ឆេទ និងមណ្ឌលទាំង៤ គឺ៖
- **មណ្ឌលខេត្តព្រះសីហនុ** ជ្រើសរើសយកបេក្ខភាពចំនួន ០២គូ ដែលមកពី ខេត្តព្រះសីហនុ ខេត្តកោះកុង ខេត្តកំពត និងខេត្តកែប **នៅថ្ងៃចន្ទ ទី២៥ ខែមីនា ឆ្នាំ២០១៩**
- **មណ្ឌលខេត្តបន្ទាយមានជ័យ** ជ្រើសរើសយកបេក្ខភាពចំនួន ០២គូ ដែលមកពីខេត្តបន្ទាយមានជ័យ ខេត្តសៀមរាប ខេត្តបាត់ដំបង ខេត្តពោធិ៍សាត់ ខេត្តប៉ៃលិន និងខេត្តឧត្តរមានជ័យ **នៅថ្ងៃព្រហស្បតិ៍ ទី២៨ ខែមីនា ឆ្នាំ២០១៩**
- **មណ្ឌលខេត្តស្វាយរៀង** ជ្រើសរើសយកបេក្ខភាពចំនួន ០២គូ ដែលមកពី ខេត្តស្វាយរៀង ខេត្តព្រៃវែង ខេត្តកំពង់ចាម ខេត្តត្បូងឃ្មុំ ខេត្តក្រចេះ ខេត្តស្ទឹងត្រែង ខេត្តមណ្ឌលគិរី និងខេត្តរតនគិរី **នៅថ្ងៃអាទិត្យ ទី៣១ ខែមីនា ឆ្នាំ២០១៩**
- **មណ្ឌលរាជធានីភ្នំពេញ** ជ្រើសរើសយកបេក្ខភាពចំនួន ០៤គូ ដែលមកពី រាជធានីភ្នំពេញ ខេត្តកណ្តាល ខេត្តតាកែវ ខេត្តកំពង់ឆ្នាំង ខេត្តកំពង់ស្ពឺ ខេត្តកំពង់ធំ និងខេត្តព្រះវិហារ **នៅថ្ងៃអង្គារ ទី០២ ខែមេសា ឆ្នាំ២០១៩**

៣. **លក្ខណៈសម្បត្តិសម្រាប់បេក្ខជនមាន៖**
- ជាកម្មករ-កម្មការិនី **កំពុងធ្វើការងារយ៉ាងតិចបីខែ** ក្នុងវិស័យឧស្សាហកម្ម ផ្នែកវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង និងវិស័យសេដ្ឋកិច្ចផ្សេងៗទៀត។
- មានកម្ពស់ចាប់ពី **១.៧០ម** សម្រាប់បេក្ខជន និង**១.៦០ម** សម្រាប់បេក្ខនារី និងមាន**អាយុចាប់ពី ១៨ឆ្នាំ ដល់៣៥ឆ្នាំ**។

៤. **វគ្គផ្តាច់ព្រ័ត្រ** នឹងប្រព្រឹត្តទៅនៅ **ថ្ងៃពុធ ១២រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០១ ខែឧសភា ឆ្នាំ ២០១៩ វេលាម៉ោង១៧:០០នាទី នៅស្ថានីយទូរទស្សន៍បាយ័នស្ទឹងមានជ័យ។**

សេចក្តីដូចបានជម្រាបជូនខាងលើ សូមសាធារណជន បងប្អូនកម្មករនិយោជិត និយោជក អង្គការសហជីព មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃពុធ ៨រោច ខែមាឃ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

*រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០១៩*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

GMAC

Garment Manufacturers Association in Cambodia

# ពាក្យសុំចុះឈ្មោះជាបេក្ខជន-បេក្ខនារីក្នុងកម្មវិធីសម្រស់ឯកវាយនភណ្ឌឆ្នាំ២០១៩

១. គោត្តនាមនិងនាមៈ..............................ជាអក្សរឡាតាំង..............................ទូរសព្ទផ្ទាល់ខ្លួន....................

ទូរសព្ទអ្នកជិតស្និទ្ធ..............................Facebook Name..............................ភេទ............

សញ្ជាតិ..................កម្ពស់............សង់ទីម៉ែត្រ ទម្ងន់...........គីឡូក្រាម

២. ថ្ងៃខែឆ្នាំកំណើតៈ ថ្ងៃទី.............ខែ..................ឆ្នាំ...................អាយុ...........ឆ្នាំ

៣. ទីកន្លែងកំណើតៈ ផ្ទះលេខ............ផ្លូវលេខ..........ភូមិ..............................ឃុំ/សង្កាត់..............................

ស្រុក/ខណ្ឌ.....................ខេត្ត/រាជធានី..............................................................................................

៤. ទីលំនៅបច្ចុប្បន្នៈផ្ទះលេខ..........ផ្លូវលេខ.......... ភូមិ................ឃុំ/សង្កាត់.......................ស្រុក/ខណ្ឌ............

....................................................................ខេត្ត/រាជធានី..............................................................................

៥. ស្ថានភាពគ្រួសារៈ ☐នៅលីវ ☐មានប្តី/ប្រពន្ធ

៦. កម្រិតវប្បធម៌..............................................................................................................................

៧ ថ្ងៃខែឆ្នាំចូលធ្វើការ ៖ថ្ងៃ......... ខែ.......... ឆ្នាំ........ឈ្មោះសហគ្រាស/គ្រឹះស្ថាន..............................................

អត្តលេខ...................... ការងារផ្នែក....................... តួនាទី.............................. ជំនាញការងារ..................

...............................................លេខទូរសព្ទរដ្ឋបាល...............................................ខេត្ត..................................

៨. ប្រវត្តិ និងបទពិសោធន៍ការងារកន្លងមក ធ្លាប់ធ្វើការងារអ្វីខ្លះ ?..........................................................................

៩. ស្នាដៃការងារៈ ☐ធ្លាប់ទទួលលិខិតបណ្ណសរសើរ ☐គ្មាន ☐ផ្សេងៗៈ.....................................................

១០. តើអ្នកធ្លាប់ទទួលបានការអប់រំ ផ្សព្វផ្សាយ ឬយល់ដឹងច្បាប់ស្តីពីការងារអ្វីខ្លះ ?...........................................

..............................................................................................................................................................

១១. តើអ្នកធ្លាប់បានទទួលការបណ្តុះបណ្តាលអ្វីខ្លះពីរោងចក្រ ?.................................................................................

១២. តើអ្នកចេះជំនាញសិល្បៈអ្វីខ្លះ ?...........................................................................................................

១៣. ជំនាញភាសាបរទេសៈ............................................................................................................................

១៤. ចំណង់ចំណូលចិត្តៈ...............................................................................................................................

១៥. បន្ទាប់ពីជាប់ជ័យលាភីសម្រស់ឯកប្រចាំឆ្នាំ២០១៩ តើអ្នកនឹងធ្វើអ្វីដើម្បីអភិវឌ្ឍការងាររបស់អ្នក ?......................

..............................................................................................................................................................

១៦. តើអ្នកនឹងជួយការងារសង្គមអ្វីខ្លះ ?.......................................................................................................

..............................................................................................................................................................

..............................................................................................................................................................

................ថ្ងៃទី ខែ ឆ្នាំ២០១៩

ស្នាមមេដៃស្តាំ/ហត្ថលេខា

**បញ្ជាក់**៖-បេក្ខជន-បេក្ខនារីសូមភ្ជាប់នូវរូបថតមួយជំហរខ្លួនមួយសន្លឹក និងថតចម្លងបណ្ណសម្គាល់បម្រើការងារនៅរោងចក្រ ០១ច្បាប់

-ទីតាំងដាក់ពាក្យ នៅទីស្តីការក្រសួង ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី/ខេត្តទាំង២៥